00224574

**Declassified to Public**
**06 September 2012**

D 99/3/11

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 09 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Tuy

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| **សំណុំរឿងលេខ៖** | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២) |
| **កាលបរិច្ឆេទឯកសារ៖** | ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន៖** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម៖** | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ៖** | សាធារណៈ |

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសំណើរបស់ អៀង សារី សុំដាក់អំណះអំណាង ឆ្លើយនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រឆាំងនឹង ឌុច

---

**បញ្ជូនដោយ៖**
**ការិ.សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Alex BATES

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ចម្លងជូន៖**
**ក្រុមមេធាវីរបស់ជនត្រូវចោទ ៖ កាំង ហ្គេកអ៊ាវ៖**
លោក ការ សាវុត្ថ
លោក Francois ROUX

**ក្រុមមេធាវីការពារក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យង់ ផានិត
លោកស្រី Silke STUDZINSKY

**ក្រុមមេធាវីការពារក្តីរបស់អ្នកដាក់ពាក្យឈ្មោះ អៀង សារី ដែលមិនមែនជាភាគី៖**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## ១. សេចក្តីផ្តើម

១. អ្នកដាក់ពាក្យសុំឈ្មោះ អៀង សារី មិនមែនជាភាគីនៅក្នុងសំណុំរឿងលេខ ០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ **ឌុច** ("សំណុំរឿងលេខ ០០១") ទេហើយក៏មិនមែនជាភាគីទៅនឹងដំណើរការនីតិវិធី នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះដែរ ។ ទោះជាយ៉ាងនេះក៏ដោយក៏ អៀង សារី បានដាក់ពាក្យសុំមួយ[1] ដើម្បីសុំដាក់អំណះអំណាងស្តីអំពី "ទិដ្ឋភាពតាមផ្លូវច្បាប់" ស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ។ អៀង សារី ក៏បានស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ផងដែរ ប្រយោជន៍ដើម្បីឱ្យខ្លួនអាចបាន ដាក់ពាក្យសុំបែបនេះ ។

២. អ្នកដាក់ពាក្យសុំបានអះអាងថា៖ ទី១) ខ្លួនមានផលប្រយោជន៍ជាក់ស្តែងនៅក្នុងលទ្ធផលនៃបណ្តឹងឧទ្ធរណ៍នេះ ដោយហេតុថាខ្លួន [ត្រូវចោទប្រកាន់] ជាចំណែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ដូច **ឌុច** ដែរ[2] ។ ទី២) បញ្ហាទាំងឡាយដែលទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នេះមានភាព "ស្មុគស្មាញ" ធ្វើឱ្យកិច្ចអន្តរាគមន៍របស់ខ្លួនផ្តល់ភាពងាយស្រួលដល់អង្គបុរេជំនុំជម្រះ[3] ។ ទី៣) "សមភាពខាងនីតិវិធី" ជាមួយនឹងសហព្រះរាជអាជ្ញា តម្រូវឱ្យអ្នកដាក់ពាក្យសុំបានដឹងឮអំពីបណ្តឹងឧទ្ធរណ៍នេះ បើពុំដូច្នោះទេ នឹងមានការបំពានលើគោលការណ៍ស្តីពីសមភាពនៃអំណាច[4] ។ ទី៤) ដំណោះស្រាយអំពីបញ្ហានេះ ជាផលប្រយោជន៍ខាងសេដ្ឋកិច្ចរបស់តុលាការ[5] ។ ទី៥) បញ្ហានេះតម្រូវឱ្យមានសវនាការផ្ទាល់មាត់

[1] ករណីរបស់ ឌុច, សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីអំពី ការអនុវត្តន៍នូវ ការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២), ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* ពាក្យសុំ] ។

[2] ពាក្យសុំ, កថាខណ្ឌទី ១ ។

[3] ពាក្យសុំ, កថាខណ្ឌទី ២ ។

[4] ពាក្យសុំ, កថាខណ្ឌទី ២ ។

[5] ពាក្យសុំ, កថាខណ្ឌទី ៣ ។

00224576

D 99/3/11



មួយដើម្បីឱ្យគេ "បានពិនិត្យយ៉ាងល្អិតល្អន់តាមរបៀបតម្លាភាព យុត្តិធម៌ និងដោយពេញលេញបរិបូរណ៍"[6] ។

៣. សហព្រះរាជអាជ្ញា ស្នើឱ្យអង្គបុរេជំនុំជម្រះ បដិសេធការដាក់ពាក្យសុំ ដោយហេតុថាវាមិនអាចទទួលយកបាន ពីព្រោះ ៖

i. អ្នកដាក់ពាក្យសុំ មិនមែនជាភាគីនៅក្នុងសំណុំរឿងលេខ 00១ ប្រឆាំងនឹង **ឌុច** ទេ និងមិនមានសិទ្ធិក្នុងការប្តឹងនៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះដែរ ។

ii. ចំពោះវិសាលភាពទូលំទូលាយដែលគេអាចពិចារណាថា ឱ្យមានការដាក់សារណាពីសំណាក់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* (*amicus curiae* brief) ក៏ស្ថានភាពរបស់អ្នកដាក់ពាក្យសុំនោះមិនត្រូវទៅតាមការសាកល្បងតាមផ្លូវច្បាប់ទេ ។

៤. ដោយហេតុថា អ្នកដាក់ពាក្យសុំមិនមានសិទ្ធិក្នុងការប្តឹងនៅក្នុងដំណើរការនីតិវិធី លើបណ្តឹងឧទ្ធរណ៍នេះ ដូច្នេះ ពាក្យសុំនោះគឺមិនមានការទាក់ទងអ្វីទេ ហើយសេចក្តីសង្កេតរបស់ខ្លួនមិនត្រូវបានយកទៅពិចារណាឡើយ ។

## ២. សេចក្តីសំអាង

### ក. អ្នកដាក់ពាក្យសុំមិនមែនជាគូភាគីនៃសំណុំរឿងលេខ 00១ ដែលប្រឆាំងនឹង ឌុច នោះទេ

៥. អ្នកដាក់ពាក្យសុំ បានទាមទារសិទ្ធិដើម្បីធ្វើអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ដោយបាននិយាយថា គាត់គឺជា "ផ្នែកមួយ" នៃសហកម្មឧក្រិដ្ឋកម្មរួម ជាមួយគ្នានឹងជនត្រូវចោទឈ្មោះ **ឌុច** ដែរ[7] ។ គាត់បានស្នើជាយោបល់ថាអត្ថិភាព "បញ្ហាខាងអង្គហេតុ និងខាងអង្គច្បាប់ដែលស្ទើរតែដូចគ្នាបេះបិទ" ដែលទាក់ទងទៅនឹងអ្នកដាក់ពាក្យសុំដូចគ្នានឹងករណី ប្រឆាំងនឹង

[6] ពាក្យសុំ, កថាខណ្ឌទី ៤ ។

[7] ពាក្យសុំ, កថាខណ្ឌទី ៨ ។

00224577

D99/3/11



ឌុច ដែរ[8]។ នេះគឺជាមូលដ្ឋានសំខាន់ជាសារវន្ត សម្រាប់សំណើដើម្បីធ្វើអន្តរាគមន៍នេះ។ គាត់បានលើកឡើងជាសំអាងថា ការអនុញ្ញាតឱ្យអនុវត្តនូវការទទួលខុសត្រូវតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងលេខ ០០១ បែបនេះគឺការអនុវត្តរបស់វាមុខជានឹងប្រឆាំងនឹង អៀង សារី នៅក្នុងសំណុំរឿងដាច់ដោយឡែកពីគ្នាលេខ ០០២ ដោយមិនអាចជៀសផុតបានឡើយ។ ក៏ប៉ុន្តែ ការតវ៉ាជំទាស់នេះ ធ្វើមិនដឹងមិនឮចំពោះដីកាបំបែកសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដែលបានកំណត់ថា មានតែ ឌុច ម្នាក់ឯងទេ ដែលនឹងត្រូវបានធ្វើការស៊ើបសួរនៅក្នុងសំណុំរឿង[9] ។ អ្នកដាក់ពាក្យសុំ នៅតែជាភាគីមួយនៅក្នុងសំណុំរឿងលេខ ០០២ ជាដដែលតែប៉ុណ្ណោះ។ គាត់អាចមានសិទ្ធិតវ៉ាជំទាស់នឹងសហកម្មឧក្រិដ្ឋកម្មរួម ឬពាក្យសុំអំពីសហកម្មឧក្រិដ្ឋកម្មរួមនេះនៅក្នុងសំណុំរឿងលេខ ០០២ បាន ដែលនៅក្នុងនោះគាត់កំពុងត្រូវបានធ្វើការស៊ើបសួររួមគ្នាជាមួយ ឌុច។

៦. គ្មានបទបញ្ញត្តិណាមួយនៅក្រោមវិធានផ្ទៃក្នុង ("វិធាន") និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") អនុញ្ញាតឱ្យគូភាគីមួយនៅក្នុងករណីមួយ ធ្វើអន្តរាគមន៍នៅក្នុងដំណើរការនីតិវិធីនៃករណីដែលបានធ្វើការស៊ើបសួរដាច់ដោយឡែកមួយផ្សេងទៀតនោះទេ ។ វិធាន បានកំណត់លើនិយមន័យនៃភាគី ដែលមានន័យត្រឹមតែ "សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនសង្ស័យ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី"[10] ។ វិធាន ៧៧.៣ ដែលគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ចែងថា អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍តាមសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ "បន្ទាប់ពីការពិចារណាលើទស្សនៈផ្សេងៗរបស់ *ភាគី* [សេចក្តីបញ្ជាក់បន្ថែមជា *អក្សរទ្រេត*]" ។ ស្រដៀងគ្នានេះដែរ វិធាន៧៧.១០ ដែលគ្រប់គ្រងលើសវនាការផ្ទាល់មាត់ចែងថា អង្គបុរេជំនុំជម្រះ អាចស្តាប់លើការសង្កេតផ្សេងៗធ្វើឡើងដោយសហព្រះរាជអាជ្ញា និង "មេធាវីរបស់ *ភាគីទាំងនោះ* បាន" [សេចក្តីបញ្ជាក់បន្ថែមជា *អក្សរទ្រេត*]" ។ អង្គបុរេជំនុំជម្រះ បានធ្វើការកត់សម្គាល់ខ្លួនឯងរួចហើយអំពីលក្ខណៈដាច់គ្នានៃសំណុំរឿងលេខ ០០១ និង ០០២ ព្រមទាំងបានទទួលស្គាល់ថា ភាគីណាមួយនៅក្នុង

[8] ពាក្យសុំ, កថាខណ្ឌទី ១០ ។

[9] ដីកាបំបែកសំណុំរឿង, D18, ចុះថ្ងៃទី១៩ កញ្ញា ២០០៧, លេខERN 00147589-00147590 (ភាសាអង់គ្លេស) ។

[10] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី២) ចុះថ្ងៃទី៥ កញ្ញា ២០០៨ សន្ទានុក្រម និយមន័យនៃភាគី [*ចាប់ពីនេះតទៅហៅថា៖ វិធាន*]។

សំណុំរឿងលេខ ០០១ គឺជា "*ភាគីទីបី*" នៅក្នុងដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ ០០២[11] ។

៧. ហេតុដូច្នេះហើយ នៅក្រោមវិធាន ឬ CPC អ្នកដាក់ពាក្យសុំនេះមិនត្រូវបានពិចារណាថាជាភាគីនៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះទេ ។

**ខ. អ្នកដាក់ពាក្យសុំមិនបានបំពេញតាមការសាកល្បងផ្លូវច្បាប់របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី**

៨. ឱកាសតែមួយគត់ដែលវិធានអនុញ្ញាតឱ្យមានការធ្វើអន្តរាគមន៍នៅក្នុងដំណើរការនីតិវិធី នៅចំពោះអ.វ.ត.ក ពីអ្នកដែលមិនមែនជាភាគីនៃរឿងក្តី គឺប្រសិនបើពួកគេមានឋានៈជា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី (amicus curiae)* ដូចមានចែងនៅក្នុងវិធាន ៣៣ ។

៩. អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការ "អញ្ជើញ ឬ ផ្តល់ការអនុញ្ញាតដល់" អង្គការមួយឬបុគ្គល ណាម្នាក់ដាក់នូវសារណាក្នុងនាមជាអ្នកដែលមិនមែនជាភាគីនៃរឿងក្តីប្រសិនបើខ្លួនពិចាណាឃើញថាសារណានេះមានលក្ខណៈគួរឱ្យចង់បាន "*សម្រាប់ការវិនិច្ឆ័យលើរឿងក្តីមួយឱ្យបានត្រឹមត្រូវ*"[12]។ កាលពីពេលកន្លងទៅអង្គបុរេជំនុំជម្រះបានប្រើឆន្ទានុសិទ្ធិបែបនេះដោយអនុលោមតាមតម្រូវការចាំបាច់នៃសភាពការជាក់ស្តែង។ នៅក្នុងករណីមួយចំនួន ខ្លួនបានសុំឱ្យ "អង្គការនានានិងសាធារណៈជន" ជួយចំពោះ"កិច្ចការទាំងឡាយ[នៅក្នុង]បណ្តឹង

[11] *ករណីរបស់ នួន ជា* ដីកាសម្រេចលើសំណើសុំដកផ្នែកមួយចំនួនចេញពីសាលដីកាសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន របស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ-០១) ចុះថ្ងៃទី២៤ មេសា ២០០៨ [*ចាប់ពីនេះតទៅហៅថា៖* ដីកាសម្រេចលើករណីរបស់ នួន ជា] ។

[12] វិធាន ៣៣.១

ឧទ្ទរណ៍"[13] ។ ក្នុងឱកាសផ្សេងទៀត សំណើសុំដាក់សារណាអំពីបញ្ហាជាក់លាក់នានារបស់អ្នកប្រកបអាជីពជាអ្នកច្បាប់ដែលតុលាការមិនបានសុំឱ្យដាក់នោះត្រូវបានបដិសេធចោល[14] ។

១០. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំមានបទប្បញ្ញត្តិណាចែងទាក់ទិននឹងអ្នកដែលមិនមែនជាភាគីនៃរឿងក្តីទេ។ ក៏ប៉ុន្តែវិធាន ៣៣ មានលក្ខណៈស្រដៀងគ្នាទៅនឹងបទប្បញ្ញត្តិនានារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី("ICTY") និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR")[15] ។ ឆន្ទានុសិទ្ធិក្នុងការទទួលយកអ្នកដែលមិនមែនជាភាគីនៃរឿងក្តីត្រូវបានអនុវត្តតាមរយៈការវាយតម្លៃទៅលើភាពពាក់ព័ន្ធរបស់សារណាដែលដាក់ជូន និងជំនួយដែលសារណានោះនឹងផ្តល់ចំពោះតុលាការ"[16] ។ ហេតុដូច្នេះ រាល់សំណើសុំដាក់សារណាចាំបាច់ត្រូវតែរួមបញ្ចូល "ទឡ្ហីករណ៍ច្បាប់និងអង្គហេតុជាក់លាក់" ទាក់ទងនឹងមូលហេតុដែលនាំឱ្យសារណានោះ "អាចគួរឱ្យចង់បានដើម្បីឱ្យមានការសម្រេចទៅលើរឿងក្តីមួយបានត្រឹមត្រូវ"[17] ។

១១. ដោយអនុវត្តនូវបទប្បញ្ញត្តិទាំងនេះ តុលាការទាំងនោះបានបដិសេធការដាក់ពាក្យសុំរបស់ជនជាប់ចោទមួយចំនួនដែលស្នើសុំអន្តរាគមន៍ក្នុងនាមជាអ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៃជនជាប់ចោទដទៃទៀតដែរ ។ ឧទាហរណ៍ ICTR បានបដិសេធចោលនូវពាក្យសុំរបស់ *Bisengimana* ដែលសុំតាំងខ្លួនជាអ្នកដែលមិនមែនជាភាគីនៃរឿងក្តី នៅក្នុងដំណើរការនីតិវិធីប្រឆាំងនឹងឈ្មោះ*Semanza* ។ ក្នុងការបដិសេធចំពោះសំណើនេះ អង្គជំនុំជម្រះសាលា

---

[13] *ករណី អៀង សារី* សេចក្តីជូនដំណឹងជាសាធារណៈ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៣) ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៨, C22/I/10 ។

[14] ករណី អៀង សារី, សេចក្តីសម្រេចស្តីពីសំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ ១២), ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨, A190/II/6 ។

[15] វិធាន ICTY, វិធាន៧៤; វិធាន ICTR; វិធាន ៧៤ ។

[16] ករណី Prosecutor v. *Bagosora*, et al., ICTR-98-41-T, សេចក្តីសម្រេចចំពោះសំណើរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដោយអង្គការ African Concern, ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៥ ។

[17] ករណី Prosecutor v. *Bagosora*, et al., ICTR-98-41-T, សេចក្តីសម្រេចចំពោះសំណើរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដោយអង្គការ African Concern, ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៨ ។

ឧទ្ធរណ៍យល់ឃើញថា ការធ្វើអន្តរាគមន៍របស់ *Bisengimana* នឹងមិនអាចជួយខ្លួនក្នុងការធ្វើសេចក្តីសម្រេចមួយឱ្យបានត្រឹមត្រូវទៅលើបណ្តឹងឧទ្ធរណ៍របស់ *Semanza* ឡើយ ។ ទាក់ទងនឹងការបារម្ភរបស់ *Bisengimana* ដែលថាសិទ្ធិរបស់គាត់អាចត្រូវបានរំលោភដោយសេចក្តីសប្រេចក្នុងករណី*Semanza* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថា វាគឺជាករណីយកិច្ចរបស់អង្គជំនុំជម្រះក្នុងការការពារសិទ្ធិរបស់ *Bisengimana* ក្នុងអំឡុងពេលសវនាការទៅលើរូប*គាត់*[18] ។

១២. ស្រដៀងគ្នានេះដែរ តុលាការ ICTR បានបដិសេធលើពាក្យសុំរបស់ជនជាប់ចោទឈ្មោះ *Kanyarukiga* ដែលស្នើសុំចូលបង្ហាញខ្លួន ដូចក្នុង*សារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងករណី* របស់ជនជាប់ចោទឈ្មោះ *Kayishema*។ នៅក្នុងពាក្យសុំនោះ បានលើកឡើងយ៉ាងច្បាស់ថា គោលបំណងនៃពាក្យសុំនេះ គឺដើម្បី "ការពារផលប្រយោជន៍របស់ [*Kanyarukiga*]"។ តុលាការបានសម្រេចថា "តួនាទីនៃ*សារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី* គឺមិនមែនដើម្បីការពារផលប្រយោជន៍ណាមួយក្រៅពីជួយដល់អង្គជំនុំជម្រះ ដើម្បីធ្វើការសម្រេចរឿងក្តីណាមួយឱ្យបានត្រឹមត្រូវនោះទេ"។ សារណាដែលបានដាក់ គឺដើម្បីគោលបំណងតែមួយគត់ក្នុងការការពារផលប្រយោជន៍របស់ខ្លួនផ្ទាល់ គឺមានវិសមិតភាពទៅនឹងភាពមិនលំអៀងដែលទន្ទឹងចង់បាន *សារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី* នោះហើយ[19]។

១៣. នៅក្នុងករណីរបស់ *Brdjanin* បានលើកឡើងថា អ្នកដាក់ពាក្យសុំអាចផ្សេងគ្នាពីករណីរឿងក្តីបច្ចុប្បន្ននេះ ដោយសារអង្គជំនុំជម្រះនៃតុលាការ ICTY បានស្វែងរកជំនួយពីសមាគមមេធាវីការពារក្តី ហើយគឺមិនមែនបុគ្គលជនជាប់ចោទរូបនោះទេ[20]។

---

[18] ករណី *Semanza* v. Prosecutor, ICTR-97-20-A, សេចក្តីសម្រេចចំពោះការដាក់ពាក្យសុំតាំងខ្លួនជាអ្នកមិនមែនជាភាគីនៃរឿងក្តី របស់ Paul Bisengimana ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៥ ។

[19] *ករណីរឿងក្តីរបស់សហព្រះរាជអាជ្ញា ទល់នឹង Kayishema,* សំណុំរឿងលេខ ICTR-2005-87-I សេចក្តីសម្រេចស្តីពី*សារណារបស់អ្នកដែលមិនមែនជាគូភាគីនៅក្នុងរឿងក្តី* សំណើមេធាវីរបស់ Gaspard Kanyarukiga កថាខណ្ឌទី ៦ ។

[20] *ករណីរឿងក្តីរបស់សហព្រះរាជអាជ្ញា ទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-A សេចក្តីសម្រេចលើសំណើរបស់សមាគមមេធាវីការពារក្តី ដែលសុំចូលរួមនៅក្នុងវេញដោយផ្ទាល់មាត់ ចុះថ្ងៃទី០៧ វិច្ឆកា ២០០៥។

00224581

D 99/3/11



១៤. អង្គបុរេជំនុំជម្រះ មិនបានស្វែងរកយោបល់ពី *សារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី* នៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះទេ។ ទោះបីជាយ៉ាងណាក្តី អ្នកដាក់ពាក្យសុំមិនមានលក្ខណៈសម្បត្តិធ្វើជា *អ្នកជូនសារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី* បានទេ ព្រោះដោយគាត់បានទទួលស្គាល់ថា "ផលប្រយោជន៍ដ៏ច្បាស់មួយនៅក្នុងការចេញជាលទ្ធផលនៃបណ្តឹងឧទ្ធរណ៍"[21]។

## គ. សេចក្តីសន្និដ្ឋានបន្ថែម

១៥. អ្នកដាក់ពាក្យសុំបានលើកឡើងរួចហើយ អំពីភាពដែលអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ ០០២[22]។ អាស្រ័យហេតុនេះ វាធ្វើឱ្យមានការយល់ខុសថាវាមានន័យបង្កប់ថា គាត់នឹងមិនត្រូវបានតុលាការស្តាប់លើបញ្ហានេះទេ។ ការលើកឡើងរបស់គាត់ដែលយោងទៅលើអវត្តមាននៃ "សមភាពខាងនីតិវិធី" នោះគឺខុស៖ គោលការណ៍ស្តីពីសមភាពនៃអំណាច អាចអនុវត្តបានតែទៅលើគូភាគីដែលនៅក្នុងករណីរឿងក្តីជាមួយគ្នាតែប៉ុណ្ណោះ។

១៦. អ្នកដាក់ពាក្យសុំទាមទារថា គួរតែអនុញ្ញាតឱ្យគាត់បានចូលរួមដើម្បីធ្វើអន្តរាគមន៍ ដោយសារសេចក្តីសម្រេចចិត្តមួយលើបញ្ហានានានៅក្នុងបណ្តឹងឧទ្ធរណ៍នេះ "នឹងមានផលប៉ះពាល់យ៉ាងធំធេងទៅលើរយៈពេល ការចំណាយ និងវិសាលភាពនៃកិច្ចស៊ើបសួរ [ដាច់ដោយឡែកពីគ្នា]" ប្រឆាំងនឹងរូបគាត់។ នេះគឺខុស។ សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងលេខ ០០២ បានស្នើសុំឱ្យគ្រប់ភាគីទាំងអស់ដាក់ជូនសារណាបន្ថែមទៀត លើពាក្យសុំអំពីសហកម្មឧក្រិដ្ឋ

---

[21] ពាក្យសុំ, កថាខណ្ឌទី ១ ។

[22] *ករណីរបស់ អៀង សារី,* ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE), សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី ២៨ កក្កដា ២០០៨, លេខERN 00208225-00208240, D97 ។

កម្ពុជា[23] ហើយគ្មានអ្វីគួរឱ្យសង្ស័យនោះទេ ត្រូវតែយកទស្សនៈយល់ឃើញទាំងនោះមកធ្វើការពិនិត្យពិចារណាក្នុងពេលដឹកនាំការស៊ើបសួរដាច់ដោយឡែកនៅក្នុងករណីរឿងក្តីនោះ។

១៧. វិធាន ៧៧.៣.ខ ផ្តល់ឆន្ទានុសិទ្ធិដល់អង្គបុរេជំនុំជម្រះក្នុងការកំណត់ បណ្តឹងឧទ្ធរណ៍ជាសារណាលាយលក្ខអក្សរតែឯកឯង បន្ទាប់ពី *"ការពិចារណាលើទស្សនៈរបស់ភាគី"* ។ សហព្រះរាជអាជ្ញា បញ្ជាក់ម្តងទៀតអំពីទឡ្ហីករណ៍របស់ខ្លួនប្រឆាំងនឹងសវនាការផ្ទាល់មាត់[24] ។ ក្រុមមេធាវីការពារក្តីរបស់ **ឌុច** ក៏ធ្លាប់បានស្នើថា ពុំចាំបាច់មានសវនាការផ្ទាល់មាត់ទេក្នុងការកំណត់អំពីបណ្តឹងឧទ្ធរណ៍នេះ[25] ។ ហេតុដូច្នេះ ទស្សនៈរបស់អ្នកដាក់ពាក្យសុំ *ដែលមិនមែនជាភាគីនៃរឿងក្តី (amicus curiae)* ឬ មិនមែនជាភាគីណាមួយ (a party) នៅក្នុងរឿងក្តីនេះ គឺមិនជាប់ទាក់ទងទេ ។

## ៣. សំណើ

១៨. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធការដាក់ពាក្យនោះចោល ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT

[23] ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី១៦ កញ្ញា ២០០៨, លេខERN 00224208-00224209, D97/III (ភាសាអង់គ្លេស) ។

[24] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ **ឌុច**, ចុះថ្ងៃទី៥ កញ្ញា ២០០៨, លេខERN 00221998-00222027, D99/3/3 (ភាសាអង់គ្លេស), កថាខណ្ឌទី ៩ ។

[25] *ករណីរបស់ កាំង ហ្គេកអ៊ាវ,* ចម្លើយរបស់ក្រុមការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨, ចុះថ្ងៃទី ១៦ កញ្ញា ២០០៨, លេខERN 00224188-00224192, D99/3/8 (ភាសាបារាំង) ។